ACCESS
Sustainable quality services for all

Australian Aid



កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីការផ្ដល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ (ហៅកាត់ថា ACCESS) គឺជាកម្មវិធីរយៈពេល៥ឆ្នាំ (២០១៨-២០២៣) ដែលស្ថិតក្រោមការផ្ដួចផ្ដើម និងគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលីផ្ដល់តាមរយៈក្រសួងការបរទេសនិងពាណិជ្ជកម្ម (អូស្ត្រាលី)។ ក្នុងរយៈពេល៣ឆ្នាំដំបូង រដ្ឋាភិបាលអូស្ត្រាលីបានផ្ដល់ថវិកាចំនួន១៥លានដុល្លាអូស្ត្រាលីតាមរយៈកម្មវិធី ACCESS ក្នុងគោលដៅពង្រឹងនិរន្តរភាព គុណភាព និងបរិយាបន្នសេវាសម្រាប់ជនមានពិការភាព និងស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ នាពេលថ្មីៗនេះ រដ្ឋាភិបាលអូស្ត្រាលីបានផ្ដល់ថវិកាបន្ថែមចំនួន១០លានដុល្លាអូស្ត្រាលីតាមរយៈកម្មវិធី ACCESS សម្រាប់ការអនុវត្តកម្មវិធីរយៈពេល២ឆ្នាំបន្ថែមទៀត ដែលមានរយៈពេលសរុប៥ឆ្នាំ។ សង្វាក់លទ្ធផលកម្មវិធីACCESS ត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំងការផ្លាស់ប្ដូរជាយុទ្ធសាស្ត្រសំខាន់ៗ ដូចជាការចូលរួមចំណែករបស់កម្មវិធីចំពោះកិច្ចខិតខំប្រឹងប្រែងឆ្លើយតប និងការស្ដារឡើងវិញរបស់កម្ពុជាចំពោះជំងឺកូវីដ-១៩ រួមទាំងការងារអាទិភាពលើកិច្ចគាំពារសង្គម។

## ការបញ្ចប់អំពើហិង្សាលើស្ត្រី និងការលើកកម្ពស់បរិយាបន្នពិការភាព

កម្មវិធី ACCESS ធ្វើការងារជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជាសំដៅចូលរួមចំណែកក្នុងការអនុវត្តផែនការសកម្មភាពជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព។

## ការលើកកម្ពស់ការផ្ដល់សេវាប្រកបដោយនិរន្តរភាព

កម្មវិធី ACCESS ទទួលស្គាល់អំពីការវិវត្តន៍របស់ប្រទេសកម្ពុជាទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប និងកំណើនក្នុងការទទួលបានមូលនិធិពីវិស័យសាធារណៈ និងឯកជន។ កម្មវិធីនេះធ្វើការងារជាមួយក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរៀបចំផែនការ និងប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពក្នុងការផ្ដល់សេវាដល់ស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងជនមានពិការភាព ។

**ការផ្ដល់សិទ្ធិអំណាចដល់ជនមានពិការភាព**

**ការលុបបំបាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ**

**ការផ្ដល់សេវាប្រកបដោយគុណភាព និងមាននិរន្តរភាព**

**ការស្ដារឡើងវិញ និងឆ្លើយតបចំពោះជំងឺកូវីដ-១៩**

## កម្មវិធី ACCESS នឹងផ្ដោតការយកចិត្តទុកដាក់លើលទ្ធផលរំពឹងទុកសំខាន់ៗដូចខាងក្រោម៖

ជនមានពិការភាព
- ទទួលបានការលើកកម្ពស់ផ្នែកសុខភាព ការអប់រំ និងសេដ្ឋកិច្ច
- មានលទ្ធភាពចូលរួម និងឧបត្ថម្ភដល់គ្រួសារ សហគមន៍ និងជីវិតនយោបាយ
- មានបទពិសោធន៍នឹងការរើសអើងតិចជាងមុន
- ធ្វើឱ្យមានការប្រសើរឡើងផ្នែកសតិអារម្មណ៍ពីតម្លៃខ្លួនឯង ទំនុកចិត្ត និងឯករាជ្យភាព។

ស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ
- មានលទ្ធភាពទទួលបានការថែទាំសុខភាពដែលមានគុណភាពដោយរួមបញ្ចូលទាំងការគាំទ្រពេញលេញ ការថែទាំរបួស ការព្យាបាលបន្ទាន់ និងការធ្វើកោសល្យវិច្ច័យ។
- មានលទ្ធភាពទទួលបានការការពារផ្នែកផ្លូវច្បាប់ដែលគិតពីសិទ្ធិអ្នករងគ្រោះជាចម្បង រួមទាំងមានគណនេយ្យភាពចំពោះជនល្មើស។
- មានលទ្ធភាពទទួលបានការសម្របសម្រួលផ្នែកសេវាសង្គមផ្សេងទៀត រួមមាន ការទទួលបានព័ត៌មានចាំបាច់នៅពេលមានវិបត្តិ ទីជម្រកសុវត្ថិភាព ការគាំទ្រផ្នែកផ្លូវចិត្តសង្គម និងជំនួយជាសម្ភារ។

ACCESS

Sustainable quality services for all

Australian Aid



© WHO

ការរំពឹងទុកសំខាន់ៗនៃលទ្ធផលបញ្ចប់នៃកម្មវិធី៖

- រាជរដ្ឋាភិបាលធ្វើផែនការ និងប្រើប្រាស់ធនធានកាន់តែមានប្រសិទ្ធភាពក្នុងការគាំទ្រសេវាសម្រាប់ជនមានពិការភាព និងស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្រោមការណែនាំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- រាជរដ្ឋាភិបាលកម្ពុជា អង្គការសង្គមស៊ីវិល និងវិស័យឯកជនពង្រីកវិសាលភាព ពង្រឹងគុណភាព និងបរិយាបន្នក្នុងការផ្តល់សេវាដល់ជនមានពិការភាព និងស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រប្រកបដោយនិរន្តរភាព។

## គោលការណ៍របស់កម្មវិធី ACCESS

- ភាពជាដៃគូ ការសហការ និងកិច្ចសហប្រតិបត្តិការ
- សមធម៌ និងបរិយាបន្ន
- ការសាងភាពជាម្ចាស់ និងការប្តេជ្ញាចិត្ត
- ការគ្រប់គ្រងដែលមានលក្ខណៈនវានុវត្តន៍ និងបត់បែនតាមស្ថានការណ៍ និងមេរៀនដកពិសោធន៍
- គណនេយ្យភាពដើម្បីឱ្យលទ្ធផលដែលសម្រេចបានមាននិរន្តរភាព



© UN Women